មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCiM

cambodian center for independent media

ថ្ងៃទី ១១ ខែមិនា ឆ្នាំ ២០១៣

# អ្នកសារព័ត៌មានកម្ពុជាស្នើសុំឲ្យមានការលើកលែងទោស និងដោះលែងលោក ម៉ម សូណង់ដូ ឲ្យបានឆាប់

នេះជាបទសម្ភាសន៍រវាងអ្នកសារព័ត៌មានឯករាជ្យ ជាមួយលោក**ម៉ម សូណង់ដូ**

អ្នកសារព័ត៌មានគ្មានព្រំដែន និងមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ទាមទារឲ្យមានការដោះលែងលោក **ម៉ម សូណង់ដូ** ដែលជាម្ចាស់វិទ្យុសំបុក**ឃ្មុំ** ឲ្យបានឆាប់ និងគ្មានលក្ខខណ្ឌ ដែលការកាត់ទោសត្រូវបានបញ្ចប់ភ្លាមៗកាលពីថ្ងៃទី ៦ មិនា ពីបទញុះញុងឲ្យមានការបះបោរប្រឆាំង។

សេចក្តីសម្រេចនៃការផ្តន្ទាទោសរបស់តុលាការមួយនេះ នឹងត្រូវបានប្រកាសនៅថ្ងៃទី ១៤ ខែមិនា ខាងមុខនេះផងដែរ។

អ្នកសារព័ត៌មានឯករាជ្យបាននិយាយថា ចុងចោទមិនបានលេចមុខចំពោះការតាមដានទេ គ្មានភស្តុតាងណាត្រូវបានបង្ហាញឡើយ។ ហើយការឃុំឃាំងលោក **ម៉ម សូណង់ដូ** គឺពិតជាអយុត្តិធម៌។

លោក **ម៉ម សូណង់ដូ** បានដាក់សំណើរទៅតុលាការម្តងទៀតដោយលោកគ្មានបំណងអាក្រក់ណាមួយនោះទេ ហើយលោក មានប្រសាសន៍ថា **ខ្ញុំគ្មានកំហុសនោះទេ។** ការចោទប្រកាន់នេះគឺជាអយុត្តិធម៌ ហើយ ខ្ញុំក៏មិនអាចទទួលយកការសម្រេចសាលក្រមរបស់តុលាការនោះដែរ។

នៅ ថ្ងៃទី១ ខែតុលា ឆ្នាំ ២០១២ លោក **ម៉ម សូណង់ដូ** ត្រូវបានកាត់ទោសឲ្យជាប់ព័ន្ធនាគាររយៈពេល ២០ឆ្នាំ ពីបទញុះញង់ឲ្យមានការបះបោរ និងមានការដណ្តើមអំណាចមន្ត្រី នៅក្នុងខេត្ត ក្រចេះ ។

លោក **ម៉ម សូណង់ដូ** បានសម្ភាសន៍ដាច់ដោយឡែកមួយជាមួយអ្នកសារព័ត៌មានគ្មានព្រំដែន (RWB) ថា វិជ្ជាជីវៈខាងសារព័ត៌មាន គឺមិនមានទេនៅក្នុងប្រទេសកម្ពុជា។ អ្នកសារព័ត៌មានមិនបានធ្វើការជាអ្នកសារព័ត៌មានពិតប្រាកដនោះទេ ដោយសារតែពួកគេមានការភ័យខ្លាច និងអោនលំទោននៅពេលមានការគំរាមកំហែងបន្តិចបន្តួច។ ខ្ញុំព្យាយាមធ្វើនូវអ្វីដែលជាការងារត្រឹមត្រូវតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាខ្ញុំមិនខ្លាចនរណាឡើយ…ហើយខ្ញុំក៏មិនដើរផ្លូវនេះដើម្បីគោរពកោតក្រែងលោកនាយករដ្ឋមន្ត្រីដែរ។ ខ្ញុំធ្វើនូវអ្វីដែលខ្ញុំមានសិទ្ធិធ្វើ ហើយស្ថិតនៅក្រោមច្បាប់រដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ។ ប្រសិនបើយើងមានសិទ្ធិ ហើយយើងមិនបានប្រើប្រាស់សិទ្ធិរបស់ខ្លួនទេ នោះវាក៏គ្មានន័យនោះដែរ។

អំឡុងពេលនៃការចោទសួរ ថៅក្រមរួមទាំងការស្នើរសុំរបស់ព្រះរាជអាជ្ញាត្រូវបានច្រានចោល និងធ្វើការត្រួតពិនិត្យនូវបទឧក្រិដ្ឋនេះឡើងវិញ។ យ៉ាងណាក៏ដោយអ្នកសារព័ត៌មាននៅតែប្រឈមមុខទៅនឹងការ

ចោទប្រកាន់ក្នុងបទញុះញង់ប្រឆាំងទៅនឹងមន្ត្រីរដ្ឋាភិបាល និងប្រឆាំងទៅនឹងច្បាប់អាជ្ញាធរ។ ហើយគាត់ត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យមានការកាប់ឆ្ការព្រៃខុសច្បាប់ នេះជាហេតុធ្វើឲ្យមានការដាក់ទោសជាប់ពន្ធនាគារពី៥ ទៅ ១០ឆ្នាំ។ វានៅមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ប្រសិនបើគេចោទប្រកាន់បន្ថែមទៅលើ អ្វីដែលលោក **ម៉ម សូណង់ដូ** បានធ្វើកន្លងមក។

ការកាត់ក្តីនៅសាលាឧទ្ធរណ៍ត្រូវបានកត់សំគាល់ដោយការអានសង្ខេប របស់មន្ត្រីតុលាការដែលតំណាងឲ្យលោកម៉ម សូណង់ដូ អំពីការគាំទ្ររបស់អង្គការជាតិនិងអន្តរជាតិលើសេរីភាពសារព័ត៌មាន។ អំណះអំណាងយ៉ាងខ្លីអំពីការរួចទោស និងដោះលែង លោក ម៉ម សូណង់ដូ គឺផ្អែកទៅលើមាត្រាទី១៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដែលធានានូវសេរីភាព និងការបញ្ចេញមតិ។
លោក **ប៉ា ងួនទៀង** នាយកមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ មានប្រសាសន៍ថា វាជាលើកដំបូងដែលតុលាការកម្ពុជាយកការវិភាគឯករាជ្យចូល ទៅក្នុងការតាមដានរឿងណាមួយ ដែលវាអាចជាសញ្ញាល្អមួយសម្រាប់បញ្ហានេះ ហើយវានៅតែមានការតវ៉ាប្រឆាំង លោក **ម៉ម សូណង់ដូ** ប៉ុន្តែវាគ្មានភស្តុតាងឡើយ។ តុលាការគួរតែឲ្យគាត់រួចទោស និងដោះលែងរូបគាត់។
លោក សរ សុវណ្ណ មេធាវីលោក **ម៉ម សូណង់ដូ** បានប្រាប់ RWB ថា សេចក្តីសម្រេចរបស់តុលាការមិនអាចយល់ស្របបានទេ។ កូនក្តីរបស់ខ្ញុំមិនមានកំហុសធ្ងន់ធ្ងរចំពោះការញុះញង់នោះទេ។ បន្ទាប់ពីមានការដាក់សំណើរ រួចមក រូបគាត់ត្រូវតែបានដោះលែងឲ្យនៅក្រៅឃុំ។ ប្រសិនបើលទ្ធផលមិនដូចអ្វីដែលបានរំពឹងទុកទេ នោះតុលាការពិតជាពុំមានភាពយុត្តិធម៌ឡើយ។
លោក ស្រី ផាន់ណារា ជាភរិយារបស់លោក ម៉ម សូណង់ដូ បានប្រាប់ RWB ថា លោកស្រីនៅតែមានក្តីសង្ឃឹម ដោយសារតែការវិនិច្ឆ័យរបស់សាលាឧទ្ធរណ៍បានបង្ហាញឲ្យឃើញនូវការការពារអំណះអំណាងដ៏ត្រឹមត្រូវមួយ។

តែទោះជាយ៉ាងណា លោក អ៊ូ វីរៈ នាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្ហាញពីក្តីបារម្ភថា តុលាការអាចជាឧទាហរណ៍មួយចំពោះលោក ម៉ម សូណង់ដូ សម្រាប់ម្ចាស់កម្មសិទ្ធិអចលនទ្រព្យទាំងអស់នៅកម្ពុជា។ គាត់បន្ថែមទៀតថា អាជ្ញាធរកំពុងតែព្យាយាមគោរពច្បាប់ដោយមានការភ័យខ្លាច ហើយនេះគឺជាគោលនយោបាយរបស់លោកនាយករដ្ឋមន្ត្រី ក្នុងការទទួលខុសត្រូវចំពោះការខិតជិតមកដល់ការបោះឆ្នោត នៅខែកក្កដា ឆ្នាំ ២០១៣ ខាងមុខនេះ ហើយក៏ជាសម្ពាធរបស់អន្តរជាតិផងដែរ។

អ្នកសារព័ត៌មានឯករាជ្យបានសម្ភាសន៍ លោក **ម៉ម សូណង់ដូ** កាលពីថ្ងៃទី៤ មិនា មុនពេលសេចក្តីសម្រេចរបស់តុលាការបានចាប់ផ្តើម។

**RWB: តើលោកមានតួនាទីអ្វីនៅក្នុងសមាគមអ្នកប្រជាធិបតេយ្យ?**
***លោក សូណង់ដូ***: ខ្ញុំបានប្រាប់ទៅប្រជាជនកម្ពុជាដែលខ្ញុំជួបអំពីគោលសំខាន់នៃសេរីភាព និងរដ្ឋធម្មនុញ្ញកម្ពុជា។ ខ្ញុំតែងតែប្រើពាក្យទាំងនេះដើម្បីពន្យល់ពីសារៈប្រយោជន៍នៃការការពារសិទ្ធិរបស់ពួកគេ ដូចអ្នកទាំងអស់គ្នាត្រូវការខ្យល់ដើម្បីដកដង្ហើមដូច្នោះដែរ។ ប្រសិនបើនរណាម្នាក់យកវាចេញពីយើង ថាតើយើងនូវសល់អ្វីទៀតសម្រាប់ដកដង្ហើមទៅ? ហើយវាដូចទៅនឹងសិទ្ធិរបស់យើងអញ្ចឹងដែរ។ ប្រជាជនកម្ពុជាភាគច្រើនកាន់សាសនាព្រះពុទ្ធ ដូចនេះចូរគោរពអ្នកដទៃ និងការជ្រៀបចូលនូវវប្បធម៌អហិង្សា។ នៅពេលដែលខ្ញុំបានទៅដល់ជនបទ ខ្ញុំបានចែកថ្នាំពេទ្យ ដោយសារប្រជាជននៅទីនោះតែងតែគ្មានលទ្ធភាពដើម្បីថែរក្សាសុខភាពរបស់ពួកគេ។

**RWB: តើអ្វីទៅដែលធ្វើឲ្យលោកជាប់ឃុំឃាំង?**

**លោក សូណង់ដូ**: ទោះបីជាមានបញ្ហាសុខភាពក៏ដោយ ខ្ញុំនៅតែអាចធ្វើអ្វីដែលល្អសម្រាប់មនុស្សវ័យ ៧១ឆ្នាំរបស់ខ្ញុំ! នៅមានអារម្មណ៍ល្អ ប៉ុន្តែការជាប់ឃុំរបស់ខ្ញុំគឺជាការខុសច្បាប់។ គ្រួសាររបស់ខ្ញុំបានមកសួរសុខទុក្ខ។ ដូចនេះគួរតែនិយាយថា ខ្ញុំពិតជារីករាយនូវអ្វីដែលខ្ញុំមាន។ ក្នុងឆាកជីវិតរបស់ខ្ញុំ ម្ហូបអាហារ និងការសប្បាយមិនមែនជារឿងសំខាន់នោះឡើយ។ ខ្ញុំគិតតែពីប្រជាជនកម្ពុជា ដែលកំពុងតែចុះអន់ថយពីមួយជំនាន់ទៅមួយជំនាន់។ ខ្ញុំគិតអំពីអ្នកដឹកនាំ ដែលមិនមានជីវភាពដូចជាពួកគេ។ នៅពេលដែលខ្ញុំចេញពីមន្ទីរឃុំឃាំង ខ្ញុំនៅតែប្តេជ្ញាដដែលថានឹងការពារលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ ទោះបីជាខ្ញុំនៅក្នុងការឃុំឃាំង ខ្ញុំនៅតែបន្តធ្វើការងារជូនប្រទេសរបស់ខ្ញុំ។ នៅចុងខែកុម្ភៈនេះ យើងបានរៀបចំយុទ្ធនាការសប្បុរសមួយដើម្បីសាងសង់សាលាមួយ ក្នុងខេត្តកំពង់ចាម។ ហើយទោះជាខ្ញុំនៅក្នុងមន្ទីរឃុំឃាំង ពួកគេនៅតែរៀបចំ និងសាមគ្គីគ្នាជានិច្ច។

**RWB: តើលោកមានទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌/តុលាការក្នុងប្រទេសលោកដែរឬទេ?**

**លោក សូណង់ដូ**: ខ្ញុំដឹងថាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនស្វាគមន៍ ចំពោះទង្វើរបស់ខ្ញុំ ប៉ុន្តែខ្ញុំសម្រេចចិត្តដើម្បីប្រឈមមុខទៅនឹងការរិះគន់របស់លោក។ ខ្ញុំនឹងមិនលាក់ខ្លួនរបស់ខ្ញុំ ហើយក៏មិនចូលចិត្តវាយគេពីក្រោយដែរ។ ខ្ញុំមិនចង់ចូលជួបជាមួយលោកនាយករដ្ឋមន្ត្រីនោះទេ។ ប្រសិនបើវាកើតឡើងមែន វាប្រហែលជារឿងមួយដ៏គួរឲ្យភ្ញាក់ផ្អើលសម្រាប់ប្រជាជនកម្ពុជា។ អ្វីដែលប្រព័ន្ធយុត្តិធម៌ផ្តល់មកឲ្យខ្ញុំគឺមិនមែនអាស្រ័យលើខ្ញុំ ដើម្បីសម្រេចចិត្តទេ។ អ្វីទាំងអស់ដែលខ្ញុំអាចធ្វើបាន ជាលទ្ធផលគឺត្រូវបានគេឃុំឃាំងពី ២០ ទៅ ៣០ឆ្នាំ គឺយកជាគំរូដល់ប្រជាជនកម្ពុជាទាំងអស់។ ភាពខ្លាំងរបស់ខ្ញុំគឺមកពីហេតុការណ៍ដែលខ្ញុំមិនអាចគេចវេះបាន។ ក្តីប្រាថ្នាតែមួយគត់គឺខ្ញុំធ្វើអ្វីដែលល្អសម្រាប់មនុស្ស។ វាជារឿងដែលគួរឲ្យភ័យព្រួយដែលអ្នកមានអំណាចទាំងនោះកំពុងតែបំផ្លាញប្រទេសជាតិរបស់ខ្លួន។ ខ្ញុំបានប្តូរក្រុមការពារ ហើយឥឡូវខ្ញុំមានមេធាវីល្អបីរូប ដែលកំពុងស្វែងរកបញ្ហាច្បាប់ និងសិទ្ធិពិតប្រាកដ។ ជាការធម្មតា ករណីជាច្រើន មេធាវីមួយៗរូបធ្វើការចរចារពីរឿងក្តីជាមួយចៅក្រម ប៉ុន្តែមេធាវីរបស់ខ្ញុំបានអាននូវឯកសារសំខាន់របស់ខ្ញុំ  ថាខ្ញុំចេញពីការឃុំឃាំង ឬនៅក្នុងឃុំ គឺមិនមែនជាបញ្ហាទេ។ ខ្ញុំនៅតែបន្តធ្វើសម្រាប់យុត្តិធម៌ក្នុងប្រទេសកម្ពុជា ហើយនិងដើម្បីការពារខ្លួនខ្ញុំផ្ទាល់។ ប៉ុន្តែអ្វីទាំងអស់ខាងលើគឺខ្ញុំមិនចង់គិតនោះទេ។

**RWB: តើសហគមន៍អន្តរជាតិគួរមានតួនាទីអ្វីខ្លះក្នុងប្រទេសកម្ពុជា?**

**លោក សូណង់ដូ**: បន្ទាប់ពីធ្លាក់ក្នុងរបបប៉ុលពត ប្រជាជនកម្ពុជាបានបាត់នូវក្តីសង្ឃឹម។ ហើយនេះគឺជាកម្លាំងចិត្តិសម្រាប់ការលូតលាស់ប្រជាធិបតេយ្យ។ពេលវេលាកន្លងផុតទៅ ចំណេះដឹងរបស់ពួកគេមានការវិវត្តន៍ ហើយប្រជាជនកម្ពុជាមានការយល់ឃើញថាជាសតិសម្បជញ្ញៈមួយត្រឹមត្រូវចំពោះចរិតលក្ខណៈនៃគំនិតដែលពួកគេមិនបានយល់ច្បាស់។ ម្លោះហើយបានជាពួកគេចាប់ផ្តើមយកចិត្តទុកដាក់ទៅលើប្រទេសលទ្ធិប្រជាធិបតេយ្យធំៗ រួមមាន ប្រទេសបារាំង និងសហរដ្ឋអាមេរិក។ ជាលទ្ធផល ប្រសិនបើសហគមន៍អន្តរជាតិមិនជួយប្រទេសអ្នកទាំងនោះទេ ថាតើនរណាជាអ្នកជួយទៅ? វាជាពេលដែលបិតានៃប្រជាធិបតេយ្យ ឃើញអំពីរបៀបដែលចៅកំពុងតែធ្វើ...។

**RWB: តើអ្វីទៅជាតម្លៃនៃវិជ្ជាជីវៈខាងសារព័ត៌មាននៅកម្ពុជា?**

**លោក សូណង់ដូ**: វិជ្ជាជីវៈខាងសារព័ត៌មាន គឺមិនមាននៅក្នុងប្រទេសកម្ពុជាទេ។ អ្នកសារព័ត៌មានមិនបានធ្វើការជាអ្នកសារព័ត៌មានពិតប្រាកដនោះទេ ដោយសារតែពួកគេមានការភ័យខ្លាច និងអោនលំទោននៅពេលមានការគំរាមកំហែងបន្តិចបន្តួច។ ខ្ញុំព្យាយាមធ្វើនូវអ្វីដែលជាការងារត្រឹមត្រូវតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាខ្ញុំមិនខ្លាចនរណាឡើយ... ហើយខ្ញុំក៏មិនដើរផ្លូវនេះដើម្បីគោរពកោតក្រែងលោកនាយករដ្ឋមន្ត្រីដែរ។ ខ្ញុំធ្វើនូវអ្វីដែលខ្ញុំមានសិទ្ធិធ្វើ ហើយស្ថិតក្នុងក្រោមច្បាប់រដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ។ ប្រសិនបើយើងមានសិទ្ធិ ហើយយើងមិនបានប្រើប្រាស់សិទ្ធិរបស់ខ្លួនទេ នោះវាក៏គ្មានន័យនោះដែរ៕